**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី
## អនុបយោគកាត់ដីចេញពីគម្របព្រៃឈើឆ្នាំ ២០០២ នៅស្រុកឈូក ស្រុកអង្គរជ័យ និងស្រុកជុំគិរី ខេត្តកំពត នូវផ្ទៃដីទំហំ 1,057.7604 ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន 582 គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកៃលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ159 លេខ160 លេខ161 និង លេខ162 ចុះថ្ងៃទី 03 ខែ កញ្ញា ឆ្នាំ 2012 របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានអនុបយោគកាត់ដីចេញពីគម្របព្រៃឈើឆ្នាំ២០០២ នូវផ្ទៃដីទំហំសរុប 1,057.7604 ហិកតា សំរាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន 582 គ្រួសារ នូវផ្ទៃដីទំហំ 906.0768 ហិកតា និងរក្សាទុកជាដីសាធារណៈទំហំ 151.6836 ហិកតា ដែលក្នុងនោះរួមមានៈ

- ផ្ទៃដីទំហំ 741.2854 ហិកតា នៅភូមិមនោសុខ ឃុំតាកែន ស្រុកឈូក សម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 246 គ្រួសារ នូវផ្ទៃដីទំហំ 606.9456 ហិកតា និងរក្សាទុកជាដីសាធារណៈ ទំហំ 134.3398 ហិកតា។ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ 01 នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ 85.9949 ហិកតា នៅភូមិអូរម្កាក់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ សម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 139 គ្រួសារ នូវផ្ទៃដីទំហំ 83.3061 ហិកតា និងរក្សាទុកជាដីសាធារណៈ ទំហំ 2.6888 ហិកតា។ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ 02 នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ 143.3326 ហិកតា នៅភូមិត្បែងពក ឃុំស្រែក្នុង ស្រុកជុំគិរី សម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 110 គ្រួសារ នូវផ្ទៃដីទំហំ 135.7492 ហិកតា និងរក្សាទុកជាដីសាធារណៈ ទំហំ 7.5834 ហិកតា។ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ 03 នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ 87.1475 ហិកតា នៅភូមិតាទែន ឃុំច្រេស ស្រុកជុំគិរី សម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 87 គ្រួសារ នូវផ្ទៃដីទំហំ 80.0759 ហិកតា និងរក្សាទុកជាដីសាធារណៈ ទំហំ 7.0716 ហិកតា។ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ 04 នៃអនុក្រឹត្យនេះ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិមនោសុខ ឃុំតាកែន ស្រុកឈូក សំរាប់ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 246 គ្រួសារ ភូមិអូរម្កាក់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 139 គ្រួសារ ភូមិត្បែងពក ឃុំស្រែក្នុង ស្រុកជុំគិរី ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 110 គ្រួសារ និងភូមិតាទែន ឃុំច្រេស ស្រុកជុំគិរី ប្រទានកម្មជូនប្រជាពលរដ្ឋចំនួន 87 គ្រួសារ។

**មាត្រា ៣ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*